មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ៩

មោចតុក្កចេតសិក ៤ តែងប្រកបជាមួយអកុសលចិត្តបានទាំង ១២ ដួង ដូច្នេះទើបមានឈ្មោះថា **សព្វាកុសលសាធារណចេតសិក** (ចេតសិកកើតទូទៅគ្រប់អកុសលចិត្ត)។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

## ១ - មោហចេតសិក (Delusion)

អារម្មណេ មុយ្ហតីតិ = មោហោ អញ្ញាណំ ធម៌ដែលមានឈ្មោះថា មោហៈ ព្រោះអត្ថថា វង្វេងក្នុងអារម្មណ៍បានដល់ អញ្ញាណ។

មុយ្ហន្តិ សត្តា ឯតេនាតិ = មោហោ សភាវៈធ្វើឲ្យពពួកសត្វវង្វេង។

# លក្ខណាទិចតុក្កៈមោហៈ

១ - អញ្ញាណលក្ខណោ មានការមិនដឹង (សភាវធម៌) តាមសេចក្តីពិត ជាលក្ខណៈ

២ - អារម្មណសភាវច្ឆាទនរសោ មានការបិទបាំងសភាវៈនៃអារម្មណ៍ ជាកិច្ច

៣ - អន្ធការបច្ចុប្បដ្ឋានោ មានភាពងងឹត (ល្ងង់) ជាអាការប្រាកដ

៤ - អយោនិសោមនសិការបទដ្ឋានោ មានអយោនិសោមនសិការៈជាហេតុជិត។

** មោហៈ គឺអវិជ្ជា បានដល់ការមិនដឹងតាមសេចក្តីពិត។*

## ក្នុងទីនេះលោកសម្ដែងដល់សេចក្ដីមិនដឹងក្នុងធម៌ ៨ យ៉ាង គឺ ៖

១ - ទុក្ខេ អញ្ញាណំ សេចក្ដីមិនដឹងក្នុងទុក្ខសច្ចៈ

២ - ទុក្ខសមុទយេ អញ្ញាណំ សេចក្ដីមិនដឹងក្នុងទុក្ខសមុទយសច្ចៈ

៣ - ទុក្ខនិរោធេ អញ្ញាណំ សេចក្ដីមិនដឹងក្នុងទុក្ខនិរោធសច្ចៈ

៤ - ទុក្ខនិរោធគាមិនីបដិបទាយ អញ្ញាណំ សេចក្ដីមិនដឹងក្នុងមគ្គសច្ចៈ

៥ - បុព្វន្តេ អញ្ញាណំ សេចក្ដីមិនដឹងក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអតីត

៦ - អបរន្តេ អញ្ញាណំ សេចក្ដីមិនដឹងក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអនាគត

៧ - បុព្វន្តាបរន្តេ អញ្ញាណំ សេចក្ដីមិនដឹងក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអតីត និងអនាគត

៨ - ឥទប្បច្ចយតា បដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ សេចក្ដីមិនដឹងក្នុងបដិច្ចសមុប្បាទ គឺ មិនដឹងក្នុងធម៌ទាំងឡាយ ដែលអាស្រ័យគ្នាកើតឡើងថា "ធម៌នេះជាបច្ច័យ"។

# ២ - អហិរិកចេតសិក

(Shamelessness of consequences or to commit wrong)

ន ហិរិយតិ ន លជ្ជិយតីតិ អហិរិកោ បុគ្គលោ ធម្មសមូហោ វា បុគ្គលឬប្រជុំនៃធម៌ ឈ្មោះថា អហិរិកៈ ព្រោះអត្ថថា មិនខ្មាស គឺ មិនរង្កៀសចំពោះបាប។ កាយទុច្ចរិតាទីហិ អជិគុច្ឆនលក្ខណន្តិ ច អលជ្ជាលក្ខណន្តិ ច អហិរិកៈ មាន លក្ខណៈមិនស្អប់ខ្ពើម មិនខ្មាសចំពោះកាយទុច្ចរិតជាដើម។ អហិរិ គឺជាបដិបក្ខនឹង ហិរិ *(សេចក្តីខ្មាស ស្អប់ ឬខ្ពើមបាប)*។

# លក្ខណាទិចតុក្កៈរបស់អហិរិកៈ

១ - កាយទុច្ចរិតាទីហិ អជិគុច្ឆនលក្ខណំ អលជ្ជនលក្ខណំ វា មានការមិនខ្មើម ឬមិនខ្មាសនូវទុច្ចរិត មានកាយទុច្ចរិត ជាដើម ជាលក្ខណៈ

២ - បាបានំ ករណរសំ មានការធ្វើបាប ជាកិច្ច

៣ - អសង្កោចនបច្ចុប្បដ្ឋានំ មានការមិនថយចាកបាប ជាអាការប្រាកដ

៤ - អត្តនិ អគារវបទដ្ឋានំ មានការមិនគោរពខ្លួន គឺ មិនខ្មាសដល់ចិត្តខ្លួនឯង ជាហេតុជិត។

** អហិរិកៈ មានការមិនស្អប់ មិនខ្មើម មិនខ្មាសអំពើបាប ប្រៀបដូចសត្វត្មាតមិនខ្មើមសាកសពដូច្នោះ។*

# ៣ - អនោត្តប្បចេតសិក

(Fearlessness of consequences or to commit wrong)

ន ឱត្តប្បតីតិ = អនោត្តប្បំ ឈ្មោះថា អនោត្តប្បៈ ព្រោះអត្ថថា មិនតក់ស្លុតចំពោះបាប *(ឬមិនតក់ស្លុត មិនខ្លាចចំពោះផលនៃទុច្ចរិតកម្ម)*។ អនោត្តប្បៈ គឺជាបដិបក្ខនឹងឱត្តប្បៈ *(សេចក្តីតក់ស្លុត ខ្លាច ឬញញើតចំពោះបាប)*។

# លក្ខណាទិចតុក្កៈរបស់អនោត្តប្បៈ

១ - អនុត្តាសលក្ខណំ មានការមិនតក់ស្លុតចំពោះបាប ជាលក្ខណៈ

២ - បាបានំ ករណរសំ មានការធ្វើបាប ជាកិច្ច

៣ - អសង្កោចនបច្ចុប្បដ្ឋានំ មានការមិនថយចាកបាប ជាអាការប្រាកដ

៤ - បរាគារវបទដ្ឋានំ មានការមិនគោរពអ្នកដទៃ ជាហេតុជិត។

** អហិរិកៈ មានការមិនខ្ពើមកាយទុច្ចរិតជាដើម ដូចជ្រូកមិនខ្ពើមលាមកចំណែកអនោត្តប្បៈ មានការមិនខ្លាចក្រែង ចំពោះកាយទុច្ចរិតជាដើម ដូចសត្វមមាចមិនខ្លាចភ្លើង។*

# ៤ - ឧទ្ធច្ចចេតសិក (Restlessness)

ឧទ្ធតស្ស ភាវោ = ឧទ្ធច្ចំ ភាវៈនៃចិត្តដែលរវើរវាយ *(មិនស្ងប់)* ឈ្មោះថា ឧទ្ធច្ចៈ។

ឧទ្ធច្ចៈ មានការផ្លាទៅផ្លាមក នៃចិត្តចំពោះអារម្មណ៍ គឺរាយមាយ ប្រៀបដូចកន្ទុយទង់ត្រូវខ្យល់បក់។

# លក្ខណាទិចតុក្កៈរបស់ឧទ្ធច្ចៈ

| | |
|---|---|
| ១- អរូបសមនលក្ខណំ | មានការមិនចូលទៅស្ងប់ ជាលក្ខណៈ ដូចទឹករលកព្រោះខ្យល់បក់ |
| ២- អនវដ្ឋានរសំ | មានការមិនតាំងនៅនឹងក្នុងអារម្មណ៍ជាកិច្ច ដូចកន្ទុយទង់ត្រូវខ្យល់បក់ |
| ៣- ភន្តត្តបច្ចុប្បដ្ឋានំ | មានការភ័ន្តភាំង អណ្ដែតអណ្ដូងនៃចិត្ត ជាអាការប្រាកដ |
| ៤- អយោនិសោមនសិការបទដ្ឋានំ | មានអយោនិសោមនសិការ ជាហេតុជិត។ |